# សារលិខិតថ្វាយព្រះពរ

## សូមក្រាបបង្គំទូលថ្វាយ
## ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !

ក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយសិរីមង្គលដ៏ថ្លៃថ្លានិងឧត្តុង្គឧត្តម នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា **គម្រប់ព្រះជន្ម ៦៧ យាងចូល ៦៨ព្រះវស្សា** ទូលព្រះបង្គំជាខ្ញុំ តាងនាមឱ្យថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្នុងនាមទូលព្រះបង្គំជាខ្ញុំផ្ទាល់ និងភរិយា សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់ សម្តែងនូវអំណរសាទរ និងរីករាយប្រកបដោយទឹកចិត្តស្មោះស្ម័គ្រ? ទឹកចិត្តស្វាមីភក្តិដ៏ជ្រាលជ្រៅបំផុត និងសូមក្រាបបង្គំថ្វាយនូវព្រះមហាសព្ទសាធុការពរជ័យ បវរសួស្តី សិរីរាជមង្គល មហាប្រសើរ ថ្វាយ **ព្រះករុណាថ្លៃវិសេសជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ប្រកបដោយព្រះកាយពលមាំមួន ខ្លាំងក្លា ព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះបញ្ញាញាណភ្លឺថ្លាវាងវៃ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់ជាម្លប់ដ៏ត្រជាក់ត្រជុំដល់ប្រជារាស្ត្រខ្មែរទាំងអស់ជារៀងដរាបអង្វែងតទៅ។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមសម្តែងថ្វាយនូវកតញ្ញូកតវេទិតាធម៌យ៉ាងស្មោះស្ម័គ្របំផុត ចំពោះព្រះមហាករុណាទិគុណ ដែល **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជានិច្ចកាលតែងតែលះបង់ព្រះបញ្ញាញាណ និងព្រះកាយពល ក្នុងបុព្វហេតុបម្រើជាតិ មាតុភូមិ បម្រើព្រះពុទ្ធសាសនា ព្រមទាំងជានិមិត្តរូប នៃឯកភាពជាតិ និរន្តរភាពជាតិ ធ្វើឱ្យប្រទេសជាតិមានសន្តិភាព មានការអភិវឌ្ឍរីកចម្រើន ថ្កុំថ្កើង រុងរឿងយ៉ាងឆាប់រហ័សលើគ្រប់វិស័យ នាំមកនូវភាពសុខដុមរមនា និងសេចក្តីសុខក្សេមក្សាន្តជូនប្រជារាស្ត្រនៅទូទាំងប្រទេស។

ឆ្លៀតក្នុងឱកាសដ៏មហាបវរ និងវិសេសវិសាលនេះ ទូលព្រះបង្គំយើងខ្ញុំ សូមលើកហត្ថប្រណម្យបួងសួងដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អស់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ បុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ពិសេសបុណ្យបារមីដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** សូមព្រះអង្គតាមជួយថែរក្សាអភិបាលប្រោសព្រំព្រះសព្ទសាធុការពរជ័យគ្រប់ប្រការថ្វាយ **ព្រះករុណា ព្រះបាទនរោត្តម សីហមុនី** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រមទាំងព្រះញាតិវង្សានុវង្សសូមសមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសូមព្រះអង្គទ្រង់គង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិជាយូរអង្វែងតរៀងទៅ។

សូម **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទ្រង់ព្រះមេត្តាប្រោសទទួលនូវការក្រាបបង្គំទូលថ្វាយប្រកបដោយគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុត ពីទូលព្រះបង្គំយើងខ្ញុំ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃច័ន្ទ ៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០

**គណៈថ្នាក់ដឹកនាំ និងមន្ត្រីរាជការ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**

**និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**